FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ



បោះពុម្ពលើកទី២ ឆ្នាំទី១២ លេខ៣ ខែមេសា ឆ្នាំ២០១៥

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# ពូជឪឡឹក "ច័ន្ទអម្រឹត"

ពូជឪឡឹក "ច័ន្ទអម្រឹត" ត្រូវបានបញ្ចេញដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទនាចុងឆ្នាំ ២០០៦ បន្ទាប់ពីបានធ្វើការពិសោធន៍អស់រយៈពេលបីឆ្នាំ (២០០៣-២០០៦) កន្លងមក។

## លក្ខណៈពិសេសៗរបស់ពូជច័ន្ទអម្រឹត

ពូជឪឡឹក "ច័ន្ទអម្រឹត" មានអាយុកាលជាមធ្យមពី ៦០-៦៥ ថ្ងៃ។ វាចាប់ផ្តើមចេញផ្កាឈ្មោលនៅអាយុ ២៥-៣០ថ្ងៃ និងចេញផ្កាញីនៅរយៈពេល ៣០-៣៥ ថ្ងៃ នៅក្រោយពេលបណ្តុះគ្រាប់។ ដើមមានប្រវែងពីរ ៣-៥ ម៉ែត្រ និងបែកខ្នែងចំនួនពី ៨-១០ ខ្នែង។ ផ្លែមានរាងមូល មានឆ្នូតពណ៌បៃតងចាស់ មានទម្ងន់ជាមធ្យម ៣,០-៤,៥ គីឡូក្រាម ហើយអាចផ្តល់ទិន្នផលជាមធ្យមពី ៤៧-៥០ តោន ក្នុងមួយហិកតា។ ផ្លែមានរសជាតិផ្អែម សាច់ក្រាមមធ្យម កម្រាស់សម្បកមធ្យម និងមានកម្រិតជាតិស្ករពី ១០-១១ ភាគរយ ។

## វិធីសាស្ត្រដាំដុះ

ដំណាំឪឡឹកអាចដាំបានពីរបៀប គឺដាំដោយគ្រាប់ផ្ទាល់ និងដាំដោយបណ្តុះកូនក្នុងកន្ទោង។ ទោះជាយ៉ាងនេះក្តី ការដាំដោយបណ្តុះគ្រាប់ក្នុងកន្ទោង គឺមានភាពងាយស្រួលក្នុងការគ្រប់គ្រង និងដំណាំដុះលូតលាស់ល្អជាងការដាំដោយគ្រាប់ផ្ទាល់។

### *ការបណ្តុះគ្រាប់*

ការបណ្តុះគ្រាប់មានពីរដំណាក់កាលគឺ៖

#### ក. ដំណាក់កាលដាស់ដំណេកគ្រាប់

ដាក់ហាលគ្រាប់ពូជក្រោមពន្លឺថ្ងៃពេលព្រឹករយៈពេល ២ ម៉ោង (ពីម៉ោង ០៨-១០) បន្ទាប់មកសារយកមកដាក់ក្នុងម្លប់រយៈពេល ២ ម៉ោង។ ខ្ចប់គ្រាប់ដោយស្បៃ ឬក្រណាត់ស្តើង រួចយកទៅត្រាំរយៈពេល ៣ ម៉ោង នៅក្នុងទឹកធម្មតា ឬត្រាំ ១៥ នាទី នៅក្នុងទឹកក្តៅអ៊ុនៗដែលមានសីតុណ្ហភាព ៤៧ អង្សាសេ។

#### ខ. ដំណាក់កាលផ្អាប់គ្រាប់

- គ្រាប់ដែលត្រាំរួចត្រូវយកទៅផ្អាប់កប់នៅក្នុងដីខ្សាច់ ឬលាមកគោសើមរយៈពេលមួយយប់ និងត្រូវត្រួតពិនិត្យមើល បើឃើញសម្បកគ្រាប់ប្រេះ អាចយកទៅបណ្តុះក្នុងកន្ទោងបាន តែបើសិនជាមិនទាន់ប្រេះ ត្រូវបន្តផ្អាប់មួយយប់ទៀត។
- កូនឪឡឹកដែលបណ្តុះនៅក្នុងកន្ទោងត្រូវមានអាយុពី ៧-១០ ថ្ងៃ ទើបអាចយកទៅដាំបាន។



កូនឪឡឹកដែលមានអាយុ ៧-១០ ថ្ងៃ
ការរៀបចំខ្នែងឲ្យវារតាមទិសដៅសមស្រប
កាត់រំលោះខ្នែងដោយទុកតែ២ប៉ុណ្ណោះក្នុង១ដើម

*ការដាំដុះ*

**រង**ដាំដំណាំឪឡឹកមានទទឹង ៣ ម-៣,៥ ម ជាការល្អព្រោះឪឡឹកជាដំណាំវារ ចំណែកឯបណ្តោយរង គឺធ្វើទៅតាមស្ថានភាពដីខ្លី ឬវែង រីឯកម្ពស់រងគឺ ១០ ស.ម នៅរដូវប្រាំង និង ២០-៣០ ស.ម នៅរដូវវស្សា ហើយប្រសិនបើមានលទ្ធភាពគួរគ្របរងដោយចំបើង ឬផ្លាស្ទិកជាការប្រសើរ។ ក្នុងផ្ទៃដីមួយហិកតា គេត្រូវការគ្រាប់ពូជប្រមាណជា ៨៨៥ ក្រាម សម្រាប់ចន្លោះគុម្ព ១,៥ ម x ០,៦ ម។

*ការកាត់រំលោះខ្នែង*

ដើម្បីឲ្យដំណាំដុះលូតលាស់ល្អ គេចាំបាច់ត្រូវកាត់រំលោះខ្នែងពី ៣-៤ ខ្នែង/ដើម ជាពិសេសខ្នែងដែលដុះចេញពីគល់ដោយទុកតែដើមមេ ១ និងខ្នែងដែលដុះចេញពីគល់ ១ ក្នុងករណីដែលវាមានខ្នែងច្រើន។ ការកាត់រំលោះនេះមានបំណងកាត់បន្ថយការស្រូបយកសារធាតុចិញ្ចឹម ពីសំណាក់ខ្នែងទាំងនោះ។ ជាទូទៅគេកាត់រំលោះនៅពេលដំណាំមានអាយុពី ២៥-៣០ ថ្ងៃ ក្រោយពេលបណ្តុះកូន ឬដាំដោយគ្រាប់។ ហើយដើម្បីឲ្យផ្លែមានទំហំធំល្អ គេគួរទុកផ្លែតែ ២ ប៉ុណ្ណោះក្នុង ១ ដើម។

## ការប្រើប្រាស់ជី

**ការ**ប្រើប្រាស់ជីតាមបច្ចេកទេសនឹងនាំឲ្យទទួលបានផលខ្ពស់ និងគុណភាពផ្លែល្អ។ គេអាចប្រើជីលាមកគោ ឬជីសរីរាង្គផ្សេងទៀត សម្រាប់ដាក់ទ្រាប់បាតមុនពេលដាំក្នុងបរិមាណ ៥ ត/ហ.ត ឬ ០,៥ គ.ក្រ/ម² រួចបំប៉នជីគីមីតាមការណែនាំដូចដូចតារាងខាងក្រោម ។

| ពេលវេលាបំប៉ន | បរិមាណជីទៅតាមប្រភេទជីនីមួយៗ (គ.ក្រ/ហ.ត) | | | ពេលវេលាដាក់ជី | វិធីសាស្ត្រដាក់ជី |
|---|---|---|---|---|---|
| | ១៥-១៥-១៥ | ២០-២០-១៥+TE | ១៦-១៦-៨-១៣ S | | |
| បំប៉នលើកទី ១ | ២៥ | ២៥ | ២៥ | ៧ ថ្ងៃ ក្រោយដាំ | លាយជី ៣០ ក្រាមជាមួយទឹក ២០ លីត្រ |
| បំប៉នលើកទី ២ | ១០០ | ៥០ | ១០០ | ១៥ ថ្ងៃ ក្រោយដាំ | ដាក់ឃ្លាតពីគល់ ២៥ ស.ម |
| បំប៉នលើកទី ៣ | ១០០ | ១០០ | ១៥០ | ចាប់ផ្តើមចេញផ្កា | ដាក់ឃ្លាតពីគល់ ៣៥ ស.ម |
| បំប៉នលើកទី ៤ | ១០០ | ៥០ | ៥០ | ក្តិបមានអង្កត់ផ្ចិត ៥ ស.ម | ដាក់ឃ្លាតពីគល់ ៤០ ស.ម |

## ការប្រមូលផល

**ពូជ** "ច័ន្ទអម្រឹត" អាចប្រមូលផលបានរយៈពេលប្រមាណជា ៦០-៦៥ ថ្ងៃ ក្រោយពេលបណ្តុះគ្រាប់។ គេអាចសម្គាល់ផ្លែឪឡឹកទុំដោយសង្កេតមើលដៃឪឡឹកដែលនៅឈមនឹងផ្លែ ប្រសិនជាវាស្វិតងាប់បានន័យថាផ្លែឪឡឹកទុំ។

## ការទុកដាក់ផ្លែក្រោយពេលប្រមូលផល

**ការ**បាត់បង់ក្រោយពេលប្រមូលផលអាចបណ្តាលមកពីកត្តាធំៗបីយ៉ាងគឺ ទីមួយបណ្តាលមកពីការបំផ្លាញដោយសារផ្សិតនិងបាក់តេរី។ ទីពីរដោយសារការទុកដាក់នៅកន្លែងដែលមានសីតុណ្ហភាពមិនសមស្រប និងទីបីដោយសារការប៉ះទង្គិច។ ដូច្នេះដើម្បីចៀសវាងការខូចខាតទាំងនេះកសិករ គួរអនុវត្តតាមវិធីសាស្ត្រដូចខាងក្រោម៖

- គួរបេះឪឡឹកដោយបន្សល់ទុកទងប្រវែង ២០ ស.ម ពីផ្លែ
- ករណីដែលឪឡឹកប្រឡាក់ គួរយកក្រណាត់ជូតចៀសវាងលាងទឹក។
- ប្រើចំបើង ឬវត្ថុទន់ទ្រាប់ដើម្បីចៀសវាងការប៉ះទង្គិចពេលដឹកជញ្ជូន។
- ដាក់ផ្លែឪឡឹកនៅកន្លែងម្លប់ នឹងមានខ្យល់ចេញចូលល្អ។



សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខបច្រើសវិទ្យា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៥ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh
ទូរអក្សរ: ssophany@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh